ក

មាតិកា

I. ខុទ្ទកាល័យព្រះមហាក្សត្រ

១. ព្រះរាជក្រម

២២-០១-២០០៧ -ព្រះរាជក្រម នស/រកម/០១០៧/០០៤ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រម ឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា ១៥៩២

២. ព្រះរាជក្រឹត្យ

៣១-០១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០១០៧/០៤២ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះឯកឧត្តមចំនួន០២ រូប ១៦០២

០១-០២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០២០៧/០៤៣ ស្តីពីការសំរួលភារកិច្ច និង តែងតាំង នាយទាហានជាន់ខ្ពស់ ចំនួន ០២ រូប ១៦០៣

០១-០២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០២០៧/០៤៤ ស្តីពីការតម្លើងឋានន្តរស័ក្តិ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ១៦០៤

០១-០២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០២០៧/០៤៥ ស្តីពីការតម្លើងឋានៈឯកឧត្តម **ឈាន កាន់ឌី** ជំនួយការឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក ១៦០៨

០១-០២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០២០៧/០៤៦ ស្តីពីការតែងតាំងឯកឧត្តម **កែម មន្ថល** ជាអគ្គលេខាធិការរងរាជរដ្ឋាភិបាល មានឋានៈស្មើ រដ្ឋលេខាធិការ ១៦០៩

០៣-០២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០២០៧/០៤៨ ស្តីពីការតែងតាំងឯកឧត្តម **ឈួន គីមសាន** ជាឧកញ៉ា ១៦១០

II. រាជរដ្ឋាភិបាល

អនុក្រឹត្យ

០៦-០២-២០០៧ -អនុក្រឹត្យលេខ ១០៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៦១១

០៦-០២-២០០៧ -អនុក្រឹត្យលេខ ១០៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៦១៣

០៦-០២-២០០៧ -អនុក្រឹត្យលេខ ១០៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៦១៤

០៦-០២-២០០៧ -អនុក្រឹត្យលេខ ១០៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៦១៦
០៦-០២-២០០៧ -អនុក្រឹត្យលេខ ១១០ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១៦១៧
០៦-០២-២០០៧ -អនុក្រឹត្យលេខ ១១១ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ១៦១៩
០៦-០២-២០០៧ -អនុក្រឹត្យលេខ ១១២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៦២០
០៦-០២-២០០៧ -អនុក្រឹត្យលេខ ១១៣ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ១៦២២
០៧-០២-២០០៧ -អនុក្រឹត្យលេខ ១១៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១៦២៣

III-ការងារបណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

០៧-០២-២០០៧ -ប្រកាសលេខ ១៨១ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ជីនជីន (ខេម បូឌា) អ៊ិលធីឌី បង្កើតរោងចក្រ "ផលិតប្រដាប់ព្យួរសម្លៀកបំពាក់ និងប្រដាប់ក្មេងលេងពីប្លាស្ទិក" ដែលមានឈ្មោះថា "ជីនជីន (ខេម បូឌា) អ៊ិលធីឌី" ១៦២៥
០៧-០២-២០០៧ -ប្រកាសលេខ ១៨២ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន អ៊ិនធើណាស្យូណល ហ្វេសិន រ៉ូយ៉ាល់ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "អ៊ិនធើណាស្យូណល ហ្វេសិន រ៉ូយ៉ាល" ១៦២៧
០៧-០២-២០០៧ -ប្រកាសលេខ ១៨៣ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន មហា ហ្គាមេន បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "មហា ហ្គាមេន" ១៦២៩

២-ទីស្តីការរដ្ឋមន្ត្រីក្រសួងបរិស្ថាន

០៧-០២-២០០៧ -ប្រកាសលេខ ០៨៦ ប្រក.បស្ត ស្តីពីការបង្កើតការិយាល័យនីតិកម្ម និងវិវាទ ១៦៣១

៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងការពារជាតិ

០៧-០២-២០០៧ -ប្រកាសលេខ ០១២/២០០៧ ប្រក ស្តីពីការណែនាំអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិនអាជីពទាំងពីរភេទ នៃកងយោធពលខេមរភូមិន្ទ ១៦៣៣

៤-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៣-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨០១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ទាយណាត់ អ៊ិនធើប្រាយស៍ អិលធីឌី** ១៦៥០

០៣-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨០៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ត្រាំរហ្វ៊ឺ-អាវិខដូស៊ីន** ១៦៥២

០៣-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨១០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឆាយណាអេស៊ាន ខសមេធីក** ១៦៥៤

០៣-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨១១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធ្វីនស៍ ខនសាល់ អ៊ិន** ១៦៥៦

០៣-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨១២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ទ៉ាយហ្វ៊ូ ខនសាល់ធីង អ៊ិន** ១៦៥៨

០៣-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨១៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ិនធើណេសិនណាល ស៊ីឃ្យូរីធី អេជេនស៊ី ខូ អិលធីឌី** ១៦៦០

០៣-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨១៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ត្រាំរហ្វ៊ឺ-ម៉ុខ** ១៦៦២

០៣-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨១៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេ ធី ដាប់ប៊ែល យូ,អ៊ិន** ១៦៦៤

០៣-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨១៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **(ខេមបូឌា) ស៊ីឃ្យូរីធី ស្ទែនឌើត** ១៦៦៦

០៣-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨១៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្គោលដិន អ៊ិនធើណេសិនណាល អ៊ិនវេសមេន** ១៦៦៨

០៣-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨១៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេវ៉ឺត ឈាងខេង អ៊ីមផត អិចផត** ១៦៧០

០៣-១១-២០០៦ -លិខិតបញ្ជាក់លេខ ២៨១៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សៀង លីន អ៊ិនវេសមេន** ១៦៧២

០៣-១១-២០០៦	-លិខិតបញ្ជាក់លេខ ២៨២០ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វូម ម៉ាក (ខេមបូឌា)**	១៦៧៤
០៣-១១-២០០៦	-លិខិតបញ្ជាក់លេខ ២៨២១ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេ ស៊ី ឌី**	១៦៧៦
០៣-១១-២០០៦	-លិខិតបញ្ជាក់លេខ ២៨២២ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ទន្លេសាប បាយអូ ខេមីខល**	១៦៧៨
០៣-១១-២០០៦	-លិខិតបញ្ជាក់លេខ ២៨២៣ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ាក្រើច**	១៦៨០
០៣-១១-២០០៦	-លិខិតបញ្ជាក់លេខ ២៨២៦ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ីធីស្តារ ស៊ីទីស (ខេមបូឌា)**	១៦៨២
០៨-១១-២០០៦	-លិខិតបញ្ជាក់លេខ ២៨៣៧ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **បូណា វីតា ស្ទឹងត្រែង**	១៦៨៤
១០-១១-២០០៦	-លិខិតបញ្ជាក់លេខ ២៨៣៨ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មេឌីខល ហ្វាម៉ា & លេបំរទៀរ**	១៦៨៦

ព្រះរាជក្រម

នស/រកម/០២០៧/០០៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុឧត្តេជកក្នុងវិស័យកីឡា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភា លើកទី៥ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៦ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី២ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុង អនុសញ្ញាអន្តរជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុជួយក្នុងវិស័យកីឡា

មាត្រា ១.–

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុជួយក្នុងវិស័យកីឡា ដែលធ្វើនៅទីក្រុងប៉ារីស នាថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៥ ដោយមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយ ។

មាត្រា ២.–

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញាអន្តរជាតិនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៧

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកម.០១០៧.០២៩

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

បានជម្រាបជូនសម្ដេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
ហត្ថលេខា
គុល ផេង

លេខ: ៥៧ ច.ល
ដើម្បីចំលងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមករា ឆ្នាំ២០០៧
អគ្គលេខាធិការរងទីស្ដីការគណៈរដ្ឋមន្ត្រី
ស៊ិន វិនកេន

3/3

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អនុសញ្ញាអន្តរជាតិ
ប្រឆាំងនឹងការប្រើប្រាស់សារធាតុជំរុញក្នុងវិស័យកីឡា

សេចក្តីប្រកាសរបស់ទីក្រុងកូប៉ិនហាក
ស្តីពីការប្រឆាំងនឹងការប្រើប្រាស់សារធាតុជួយភ្លោចក្នុងកីឡា

អ្នកចូលរួម :

ដោយយល់ថាវិស័យកីឡាគួរដើរតួនាទីយ៉ាងសំខាន់ក្នុងកិច្ចការពារសុខភាព ការអប់រំសីលធម៌ និងការអប់រំកាយ និងក្នុងការលើកកំពស់ការយល់ដឹងជាអន្តរជាតិ ។

ដោយប្រុងប្រយ័ត្នថាការប្រើប្រាស់សារធាតុដូប៉ាំធ្វើអោយអន្តរាយដល់តំលៃរបស់វិស័យកីឡា ។

ដោយមានកង្វល់ពីការប្រើប្រាស់ភ្នាក់ងារ និងវិធីសាស្រ្តនៃការប្រើសារធាតុដូប៉ាំ ដោយកីឡាករតាមរយៈកីឡា និងផលវិបាកដែលបណ្តាលមកពីការប្រើប្រាស់សារធាតុ និងវិធីសាស្រ្តទាំងនេះដែលប៉ះពាល់ដល់អនាគតនៃវិស័យកីឡា ។

ដោយចងចាំទុកក្នុងចិត្តនូវច្បាប់ គោលនយោបាយ និងសេចក្តីប្រកាស ប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាំ ដែលអនុម័តដោយស្ថាប័នកីឡាជាតិ និងស្ថាប័នកីឡាអន្តរជាតិ ។

ដោយដឹងថាអាជ្ញាធរសាធារណៈ និងស្ថាប័នកីឡា មានការទទួលខុសត្រូវបំពេញអោយគ្នាទៅវិញទៅមក ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាំក្នុងវិស័យកីឡា ជាពិសេសដើម្បីធានាបាននូវការប្រព្រឹត្តសមស្របក្នុងព្រឹត្តិការណ៍កីឡា ដោយផ្អែកលើមូលដ្ឋាននៃគោលការណ៍ការចូលរួមប្រកួតស្មើភាព និងដើម្បីការពារដល់សុខភាពកីឡាករ ដែលចូលរួមក្នុងព្រឹត្តិការណ៍កីឡាទាំងនោះ ។

ដោយទទួលស្គាល់លើការរីកចំរើន ដែលធ្វើឡើងដោយរដ្ឋាភិបាលក្នុងការប្រឆាំងទៅនឹងការប្រើប្រាស់សារធាតុដូប៉ាំរហូតមកទល់នឹងពេលបច្ចុប្បន្ននេះ ជាពិសេសទាក់ទងទៅនឹងការទទួលស្គាល់អភិបាលកិច្ច និងការផ្តល់មូលនិធិដល់ទីភ្នាក់ងារពិភពលោកប្រឆាំងនឹងការប្រើប្រាស់សារធាតុ ដូប៉ាំ ការបង្កើត និងការអនុវត្តរបស់ក្រុមប្រឹក្សានៃអនុសញ្ញាអឺរ៉ុបប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាំ (ETS 135) និងពិធីសារបន្ថែមរបស់ក្រុមប្រឹក្សានេះ កិច្ចសហប្រតិបត្តិការ អន្តរដ្ឋាភិបាលស្តីពីការប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាំ ដោយរាប់បញ្ចូលទាំងការចូលរួម ចំណែករបស់ក្រុមផ្តល់ប្រឹក្សាអន្តររដ្ឋាភិបាលអន្តរជាតិស្តីពីវេទិកាប្រឆាំងនឹងការប្រើប្រាស់ សារធាតុដូប៉ាំក្នុងវិស័យកីឡា (IICGADS) និងការបង្កើតកម្មវិធីជាតិប្រឆាំងនឹងការប្រើប្រាស់ សារធាតុដូប៉ាំ ។

ដោយទទួលស្គាល់ថាក្នុងសេចក្តីថ្លែងការណ៍ចុងក្រោយ (Final Communiqué) នៃកិច្ចប្រជុំតុមូល UNESCO របស់រដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់ទទួលខុសត្រូវលើការអប់រំកាយ និងកីឡា ដែលធ្វើឡើងនៅទីក្រុងប៉ារីសនាថ្ងៃទី ៩ ដល់ថ្ងៃទី ១០ ខែមករា ឆ្នាំ ២០០៣ ដែលគាំទ្រដល់ការជំរុញអោយមានការរៀបចំអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាអោយបានឆាប់ដោយផ្អែកលើអនុសញ្ញាប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ារបស់ក្រុមប្រឹក្សាអឺរ៉ុប ប្រសិនបើ អាចធ្វើទៅបាន មុនកីឡាអូឡាំពិករដូវក្តៅឆ្នាំ ២០០៤ និងសំរាប់ការអនុម័តប្រសិនបើអាច ធ្វើទៅបាន មុនកីឡាអូឡាំពិករដូវរងាឆ្នាំ ២០០៦ ។

ដោយបានប្តេជ្ញាចិត្តអនុវត្តសកម្មភាពសហប្រតិបត្តិការបន្ថែមទៀត និង កាន់តែខ្លាំងជាងមុនក្នុងគោលបំណងកាត់បន្ថយ និងចុងក្រោយ បំបាត់ជាស្ថាពរនូវការប្រើសារធាតុដូប៉ាក្នុងវិស័យ កីឡា ។

បានឈានដល់ការយល់ដូចខាងក្រោមនេះ :

១. វិសាលភាព

ក្នុងការអនុវត្តតាមកថាខ័ណ្ឌទាំងអស់នៃសេចក្តីប្រកាសនេះ អ្នកចូលរួមត្រូវធ្វើសកម្មភាពក្នុងដែនកំនត់បទបញ្ញត្តិរដ្ឋធម្មនុញ្ញរបស់ប្រទេសរៀងៗខ្លួន និងបទបញ្ញត្តិច្បាប់ផ្សេងៗទៀត និងទទួលស្គាល់ភាពខុសគ្នាក្នុងប្រព័ន្ធរដ្ឋធម្មនុញ្ញ និងច្បាប់រវាងរដ្ឋាភិបាលនានា ដោយរួមបញ្ចូលគ្នាជាមួយនឹងវិធីសាស្ត្រចម្រុះ ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា ។

២. គោលបំណង

គោលបំណងនៃសេចក្តីថ្លែងការណ៍នេះ គឺដើម្បីផ្សព្វផ្សាយការយល់ដឹងពីនយោបាយ និងសីលធម៌ក្នុងចំណោមអ្នកចូលរួមដើម្បី :

២.១ ទទួលស្គាល់តួនាទី និងគាំទ្រដល់ទីភ្នាក់ងារពិភពលោកប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ា (WADA)

២.២ គាំទ្រច្បាប់ពិភពលោកប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ា (" ច្បាប់ ") ដែលអនុម័តដោយគណៈកម្មាធិការមូលនិធិ WADA នៅឯសន្និសីទពិភពលោកស្តីពីការប្រើសារធាតុដូប៉ាក្នុងកីឡា (ទីក្រុងកូប៉ិនហាក ថ្ងៃទី ៣ ដល់ថ្ងៃទី ៥ ខែមិនា ឆ្នាំ ២០០៣)

២.៣ ទ្រទ្រង់ដល់កិច្ចសហប្រតិបត្តិការអន្តររដ្ឋាភិបាលអន្តរជាតិ ក្នុងការបង្កើនភាពចុះសម្រុងគ្នាក្នុងគោលនយោបាយ និងការប្រតិបត្តិប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងកីឡា និង

២.៤ គាំទ្រដល់ដំណើរការទាន់ពេលវេលា ដែលនាំឆ្ពោះទៅរកអនុសញ្ញា ឬកាតព្វកិច្ចផ្សេងទៀតលើចំនុច ៣-៨ ដូចខាងក្រោម ដែលនឹងត្រូវអនុវត្តតាមរយៈលិខិតុបករណ៍សមស្របទៅនឹងបរិបទរដ្ឋធម្មនុញ្ញនិងរដ្ឋបាលរបស់រដ្ឋាភិបាលនីមួយៗ ត្រឹម ឬមុនថ្ងៃទីមួយនៃកីឡាអូឡាំពិករដូវរងាទីក្រុងទូរិន ។ ដំណើរការនេះគប្បីប្រើប្រាស់ជំនាញឯកទេសរបស់តំណាងរដ្ឋាភិបាលមកពីគ្រប់តំបន់ ទាំងអស់នៃពិភពលោក និងអង្គការអន្តរជាតិ ។

៣. ការគាំទ្រចំពោះ WADA

អ្នកចូលរួមនីមួយៗ :

៣.១ ទទួលស្គាល់តួនាទី និងគាំទ្រ WADA

៣.២ ស្ថិតក្រោមការកែសំរួលតាមរយៈសហប្រតិបត្តិការអន្តររដ្ឋាភិបាលដែលសមស្រប ប្រកាសគោលបំណងរបស់ខ្លួនដើម្បីបន្តទម្លាប់ប្រតិបត្តិ ដែលអាជ្ញាធរសាធារណៈបានអនុវត្តតាមក្នុងអភិបាលកិច្ច និងការផ្តល់ហិរញ្ញប្បទានដល់ WADA និងក្នុងក្របខ័ណ្ឌនេះ :

៣.២.១ គាំទ្រការបែងចែកសមាសភាពរបស់គណៈប្រតិភូអាជ្ញាធរសាធារណៈនៅក្នុងគណៈកម្មាធិការមូលនិធិ WADA ស្របតាមតំបន់អូឡាំពិក :

អ្នកតំណាង ៤ នាក់ មកពីទ្វីបអាមេរិក

អ្នកតំណាង ៣ នាក់ មកពីទ្វីបអាហ្វ្រិក

អ្នកតំណាង ៥ នាក់ មកពីអឺរ៉ុប

អ្នកតំណាង ៤ នាក់ មកពីទ្វីបអាស៊ី

អ្នកតំណាង ២ នាក់ មកពីទ្វីបអូសេអានី

៣.២.២ គាំទ្រការផ្តល់មូលនិធិដល់ WADA ដោយអាជ្ញាធរសាធារណៈ និងចលនាអូឡាំពិកដូចខាងក្រោម :

៣.២.២.១ អាជ្ញាធរសាធារណៈរួមចំណែកផ្តល់ ៥០% នៃគំរោងថវិកាស្នូលប្រចាំឆ្នាំរបស់ WADA ដែលបានអនុម័តរួច ។

៣.២.២.២ ការទូទាត់របស់អាជ្ញាធរសាធារណៈទៅអោយ WADA ស្របតាមតំបន់អូឡាំពិក :

ទ្វីបអាហ្វ្រិក :	០.៥០%
ទ្វីបអាមេរិក :	២៩%
ទ្វីបអាស៊ី :	២០.៤៦%
ទ្វីបអឺរ៉ុប :	៤៧.៥%
ទ្វីបអូសេអានី :	២.៥៤%

៤. គាំទ្រដល់ច្បាប់ពិភពលោកប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ា

អ្នកចូលរួមនីមួយ ១ :

៤.១ ទទួលស្គាល់តួនាទីរបស់ច្បាប់ថាជាមូលដ្ឋានគ្រឹះមួយក្នុងប្រការប្រយុទ្ធប្រឆាំងទូទាំងពិភពលោកប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងកីឡា ។

៤.២ នៅទីណាដែលសមស្រប ព្យាយាមកែសំរួលអោយបានល្អប្រសើរជាងមុននូវគោលនយោបាយ និងទម្លាប់ប្រតិបត្តិប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងកីឡា ដើម្បីអោយមានភាពស្របគ្នាជាមួយនឹងបទបញ្ញត្តិនៃច្បាប់នេះនៅទីណាដែលសមស្រប ។

៤.៣ លើកទឹកចិត្តស្ថាប័នជាតិ និងអន្តរជាតិ ដែលជាប់ពាក់ព័ន្ធក្នុងការប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងកីឡា អោយអនុម័តច្បាប់ និងអោយមានដំណើរការស្របទៅតាមច្បាប់ នៅទីណាដែលសមស្រប ។

៤.៤ ចាត់វិធានការសមស្របចំពោះការបដិសេធមិនទទួលយកជំនួយគាំទ្រផ្នែកហិរញ្ញវត្ថុខ្លះ ឬទាំងអស់របស់រដ្ឋាភិបាល ដែលទាក់ទងទៅនឹងការចូលរួមក្នុងកីឡា ដែលបានមកអង្គការកីឡា កីឡាករ និងបុគ្គលិកគាំទ្រកីឡាករ ដែលមិនអនុវត្តតាមច្បាប់ ឬវិធានប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាកំពុងមានជាធរមាន ដែលត្រូវបានអនុម័តស្របទៅតាមច្បាប់ និង

៤.៥ គាំទ្រដល់តួនាទីរបស់ WADA ក្នុងការសំរបសំរួល ធ្វើឱ្យស៊ីសង្វាក់គ្នា និងធ្វើឱ្យកិច្ចខិតខំប្រឹងប្រែងប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាមានលក្ខណៈស្តង់ដារស្របទៅតាមច្បាប់ ។

៥. វិធានការដាក់កំរិតលើការមាន ការប្រើប្រាស់សារធាតុនិងវិធីសាស្ត្រហាមឃាត់ក្នុងកីឡា

៥.១ អ្នកចូលរួមនីមួយៗមានបំណងធានាអោយបានថាបទបញ្ជា វិធានការរដ្ឋបាល និងវិធានការរបស់ស្ថាប័ននីតិប្រតិបត្តិ គឺមានរួចជាស្រេចនៅនឹងកន្លែង ដើម្បី :

៥.១.១ ត្រួតពិនិត្យការមាន (មានដូចជាការនាំចូល ការនាំចេញ ការចែកចាយ ការរត់ពន្ធ និងការផលិត) សារធាតុ និងវិធីសាស្ត្រហាមឃាត់ និង

៥.១.២ ជំរុញអោយមានការប្រាស្រ័យទាក់ទងព័ត៌មាន ដើម្បីកាត់បន្ថយការមានសាធាតុ និងវិធីសាស្ត្រហាមឃាត់ រវាងទីភ្នាក់ងារនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្នុងការធ្វើដូច្នេះ វិធានការដែលបានអនុវត្ត មិនគួររារាំងដល់ការមានសារធាតុ និងវិធីសាស្ត្រហាមឃាត់ក្នុងកីឡាសំរាប់បំរើដល់គោលបំណងស្របច្បាប់ឡើយ ។

៥.២ អ្នកចូលរួមម្នាក់ៗត្រូវបានលើកទឹកចិត្តអោយមានការចាត់វិធានការផ្សេងៗដែលទាក់ទងទៅនឹងការប្រើអាហារបំប៉នបន្ថែមក្នុងគោលបំណងអោយកីឡាករទាំងអស់អាចទទួលបានព័ត៌មានស្តីពីជំរើសចំណីអាហារបំប៉នផ្សេងៗ ដើម្បីចៀស វាងការប្រើប្រាស់សារធាតុដូប៉ាដែលបានហាមឃាត់ ។

៦. វិធានការជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ា

អ្នកចូលរួមម្នាក់ៗ គប្បីផ្តល់ជំនួយហិរញ្ញវត្ថុទៅតាមមធ្យោបាយរៀងៗខ្លួន ដើម្បីជួយគាំទ្រដល់កម្មវិធីជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ា ដែលរួមមាន វិធានការត្រួតពិនិត្យលើការប្រើប្រាស់សារធាតុដូប៉ា សកម្មភាពអប់រំ ការសិក្សាស្រាវជ្រាវ និងសកម្មភាពផ្សព្វផ្សាយព័ត៌មាន។

៧. កិច្ចសហប្រតិបត្តិការអន្តរជាតិនៅក្នុងការត្រួតពិនិត្យលើការប្រើប្រាស់សារធាតុដូប៉ា

ដោយទទួលស្គាល់ថា ការប្រយុទ្ធប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ានៅក្នុងវិស័យកីឡា គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពតែមួយគត់ ដែលក្នុងនោះ គេអាចធ្វើតេស្តលើកីឡាករដោយមិនចាំបាច់ផ្តល់ការជូនដំណឹងជាមុន និង ការទទួលគំរូរបស់រាងកាយតាមរយៈការប្រមូលសំណាក ដែលគេអាចដឹកជញ្ជូនទាន់ពេលវេលាទៅកាន់មន្ទីរពិសោធន៍ដើម្បីធ្វើវិភាគ ដូច្នេះអ្នកចូលរួមម្នាក់ៗ ត្រូវ ៖

៧.១. សហការជាមួយអង្គការ WADA និងអង្គការប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាដទៃទៀត ដែលប្រតិបត្តិការក្រោមការឧបត្ថម្ភរបស់អង្គការ WADA និងត្រូវគោរពតាមច្បាប់ បទបញ្ញត្តិរបស់ម្ចាស់សាមីប្រទេស និងត្រូវចាត់វិធានការត្រួតពិនិត្យលើការប្រើប្រាស់សារធាតុដូប៉ាចំពោះកីឡាកររបស់ខ្លួន មិនថានៅក្នុងទឹកដីរបស់ខ្លួន ឬ នៅកន្លែងផ្សេងនោះទេ។

៧.២. នៅពេលដែលសមស្រប ត្រូវសហការនៅក្នុងការបញ្ជូន ឬ ដឹកជញ្ជូនឆ្លងកាត់ព្រំដែននូវគំរូរបស់រាង កាយដែលទទួលបាន តាមរយៈការប្រមូលសំណាក។

៧.៣. នៅពេលដែលសមស្របត្រូវទទួលស្គាល់ទៅវិញទៅមកចំពោះនីតិវិធីត្រួតពិនិត្យលើការប្រើប្រាស់សារធាតុ និងការគ្រប់គ្រងលទ្ធផលនៃការធ្វើតេស្តរបស់អង្គការប្រឆាំងនឹងការប្រើសារធាតុដូប៉ា ដែលធ្វើឡើងស្របតាមច្បាប់នេះ។

៧.៤. នៅពេលដែលសមស្រប ត្រូវសហការជាមួយអង្គការ WADA នៅក្នុងការជួយសម្របសម្រួលជាអន្តរជាតិចំពោះវិធានការត្រួតពិនិត្យលើការប្រើប្រាស់សារធាតុដូប៉ាដែលអនុវត្តធ្វើឡើងដោយអង្គការប្រឆាំងនឹងការប្រើប្រាស់សារធាតុផ្សេងៗ និង

៧.៥. លើកទឹកចិត្ត និងជួយគាំទ្រដល់ការរៀបចំធ្វើតេស្តដែលធ្វើឡើងរវាងរដ្ឋាភិបាល ឬ អង្គការក្រៅរដ្ឋាភិបាលប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាដែលបានចាត់តាំងរួច។

៨. ការតាមដានត្រួតពិនិត្យលើការអនុវត្តតាម

ការត្រួតពិនិត្យលើការបន្តការគោរពតាមការសន្យា និងការប្តេជ្ញាចិត្តផ្សេងៗដែលធ្វើឡើងនៅក្នុងអនុសញ្ញានេះ ឬ ការអនុវត្តតាមកាតព្វកិច្ចផ្សេងទៀត ត្រូវធ្វើឡើងដូចបានកំនត់នៅក្នុងការពិភាក្សារវាងអង្គការ WADA និងរដ្ឋាភិបាលពាក់ព័ន្ធផ្សេងៗ។

៩. អន្តរកាល

នៅក្នុងអំឡុងពេលដែលនាំទៅដល់ការបង្កើតអនុសញ្ញាមួយ ឬ កាតព្វកិច្ចដទៃទៀត អ្នកចូលរួមទាំងឡាយអាចសុំអោយអង្គការ WADA ផ្តល់កិច្ចសហការដោយឈរលើមូលដ្ឋានជាក់ស្តែង ដើម្បីជួយដល់ការអនុវត្តបទបញ្ញត្តិនៃច្បាប់នេះ តាមសមត្ថកិច្ចជំនាញរបស់របស់រដ្ឋាភិបាល ។

សេចក្តីប្រកាសរបស់ទីក្រុង កូប៉ិនហាក ស្តីពីការប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាំនៅក្នុងវិស័យកីឡា

(ហត្ថលេខា)

ចុះហត្ថលេខានៅ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៥

តាងនាមអោយ : រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

ដោយ **បណ្ឌិត កុល ផេង**

មុខតំណែង : **ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

COPENHAGEN
DECLARATION
ON ANTI-DOPING IN SPORT

Participants:

Conscious that sport should play an important role in the protection of health, in moral and physical education and in promoting international understanding;

Mindful that doping undermines the values of sport;

Concerned by the use of doping agents and methods by athletes through sport and the consequences thereof for the future of sport;

Bearing in mind the anti-doping regulations, policies and declarations adopted by national and international sports organisations;

Aware that public authorities and sports organisations have complementary responsibilities to combat doping in sport, notably to ensure the proper conduct, on the basis of the principle of fair play, of sports events and to protect the health of those that take part in them;

Recognising the progress made by governments in anti-doping to date, particularly in relation to the recognition, governance and funding of the World Anti-Doping Agency, the development and implementation of the Council of Europe Anti-Doping Convention (ETS 135) and its Additional Protocol, inter-governmental cooperation on anti-doping, including the contribution of the International Intergovernmental Consultative Group on Anti-Doping in Sport (IICGADS) forum, and the establishment of national anti-doping programs.

Recognising that in the Final Communiqué of the UNESCO Round Table of Ministers and Senior Officials Responsible for Physical Education and Sport held in Paris on 9/10 January 2003 that argued for the acceleration of the preparation of an international Convention against Doping, based on the Council of Europe's Anti-Doping Convention, if possible, before the Summer Olympic Games of 2004 and for adoption, if possible, before the Winter Olympic Games of 2006;

Determined to take further and stronger cooperative action aimed at the reduction and eventual elimination of doping in sport;

Have reached the following understandings:

1. Scope

In pursuing all paragraphs of this Declaration, Participants act within the limits of their respective constitutional and other legal provisions and acknowledge the diversity in constitutional and legal systems between governments, combined with diverse approaches to the fight against doping in sport.

2. Purpose

The purpose of this Declaration is to articulate a political and moral understanding among Participants to:

2.1. Recognise the role of, and support, the World-Anti-Doping Agency (WADA);

2.2. Support the World Anti-Doping Code (the "Code") adopted by the WADA Foundation Board at the World Conference on Doping in Sport (Copenhagen, 3-5 March 2003);

2.3. Sustain international intergovernmental cooperation in advancing harmonisation in anti-doping policies and practices in sport; and

2.4. Support a timely process leading to a convention or other obligation on points 3-8 below, to be implemented through instruments appropriate to the constitutional and administrative contexts of each government on or before the first day of the Turin Winter Olympic Games. This process should draw upon the expertise of representatives of governments from all the regions of the world and international organisations.

3. Support to WADA

Each Participant:

3.1. Recognises the role of, and supports, WADA;

3.2. Subject to modification through appropriate intergovernmental cooperation, declares its intention to continue the practices public authorities have followed in the governance and financing of WADA and, within this framework:

3.2.1. Supports the following allocation of public authority delegates to the WADA Foundation Board according to Olympic regions:

4 representatives from the Americas;

3 representatives from Africa;

5 representatives from Europe;

4 representatives from Asia;

2 representatives from Oceania.

3.2.2. Supports the co-funding of WADA by public authorities and the Olympic movement as follows:

3.2.2.1. Public authorities contribute collectively 50% of the approved WADA annual core budget;

3.2.2.2. Public authority payments to WADA according to Olympic regions:

Africa:	0.50%
Americas:	29%
Asia:	20.46%
Europe:	47.5%
Oceania:	2.54%

4. **Support for the World Anti-Doping Code**

Each Participant:

4.1. Recognises the role of the Code as the foundation in the world wide fight against doping in sport;

4.2. Seeks to progressively adapt, where appropriate, their anti-doping policies and practices in sport to be in conformity with the provisions of the Code;

4.3. Encourages national and international organisations engaged in anti-doping in sport to adopt the code and to be in conformity with the Code, where appropriate;

4.4. Takes appropriate steps to withhold some or all government financial support related to participation in sport from sport organisations, athletes and athlete support personnel that are not in compliance with the Code or applicable anti-doping rules adopted pursuant to the Code; and

4.5. Supports the role of WADA to coordinate, harmonise and standardise anti-doping efforts according to the Code.

5. **Measures to restrict the availability and use in sport of prohibited substances and methods.**

5.1. Each Participant intends to ensure that regulations, administrative measures and, where appropriate, legislative measures are in place to:

5.1.1. Control the availability (including importation, exportation, distribution, trafficking and manufacturing) of prohibited substances and prohibited methods; and

5.1.2. Enable communication of information to reduce the availability of prohibited substances and prohibited methods between agencies within their jurisdiction

In so doing, any measures taken should not impede the availability for legitimate purposes of substances and methods prohibited in sport.

5.2. Each Participant encourages measures relating to the use of nutritional supplements in order that sports people are able to make informed choices to avoid ingestion of prohibited substances.

6. National anti-doping measures

Each Participant should provide, within their means, financial support for a national anti-doping program including doping control, education, research and information activities.

7. International cooperation in doping control

Recognising that the fight against doping in sport can only be effective when athletes can be tested with no advance notice and specimens obtained in sample collection can be transported in a timely manner to laboratories for analysis, each Participant:

7.1. Cooperates with WADA and other anti-doping organisations operating under its auspices, subject to relevant host countries' regulations, to conduct doping controls on their athletes, whether on their territory or elsewhere;

7.2. Cooperates, where appropriate, to expedite the shipping or carrying across borders of bodily specimens obtained in sample collection;

7.3. Mutually recognises, where appropriate, the doping control procedures and test results management of any anti-doping organisation that is consistent with the Code;

7.4. Cooperates, where appropriate with WADA, on the international coordination of doping controls conducted by the various anti-doping organisations; and

7.5. Encourages and supports reciprocal testing arrangements between designated government or non-government anti-doping organisations.

8. Monitoring Compliance

Ongoing compliance with the commitments reflected in the convention or other obligation will be monitored as determined in consultation between WADA and the applicable government(s).

9. **Transition**

In the period leading to a Convention or other obligation, participants may invite WADA to cooperate on a practical basis in order to assist in implementing the provisions of the Code in governments' field of authority.

Copenhagen Declaration on Anti-Doping in Sport

Signed on the 24th day of May in the year 2005

For the Government of: Royal Government of Cambodia

by

Name: Dr KOL Pheng

Title: Senior Minister and Minister of Education Youth and Sports.

អនុសញ្ញាអន្តរជាតិ
ប្រឆាំងនឹងការប្រើប្រាស់សារធាតុជួយក្នុងវិស័យកីឡា

បុព្វកថា

មហាសន្និបាតរបស់អង្គការសហប្រជាជាតិទទួលបន្ទុកលើវិស័យអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ ដែលចាប់ពីពេលនេះទៅហៅថា UNESCO នាកិច្ចប្រជុំលើកទី៣៣ នៅក្នុងទីក្រុងប៉ារីសប្រទេសបារាំងចាប់ពីថ្ងៃទី០៣ ដល់ថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៥ ។

ដោយយល់ឃើញថាគោលបំណងរបស់ UNESCO គឺដើម្បីរួមចំណែកដល់សន្តិភាព និងសន្តិសុខ ដោយជំរុញឱ្យមានកិច្ចសហប្រតិបត្តិការក្នុងចំណោមប្រជាជាតិ នានាតាមរយៈការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌

យោងតាមលិខិតុបករណ៍អន្តរជាតិដែលមានស្រាប់ ដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស

ដោយយល់ដឹងពីសេចក្តីសំរេចលេខ ៥៨/៥ អនុម័តដោយមហាសន្និបាតរបស់អង្គការសហប្រជាជាតិស្តីពីកីឡាដែលជាមធ្យោបាយ ដើម្បីលើកស្ទួយការអប់រំ សុខភាព ការអភិវឌ្ឍ និងសន្តិភាព ជាពិសេសក្នុងកថាខ័ណ្ឌ ៧ ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០០៣

ដោយដឹងថាកីឡាដើរតួនាទីយ៉ាងសំខាន់ក្នុងការការពារសុខភាព សីលធម៌ ការអប់រំកាយ និងវប្បធម៌ និងក្នុងការលើកស្ទួយការយល់ដឹងជាអន្តរជាតិ និងសន្តិភាព

ដោយកត់សំគាល់ពីតំរូវការដើម្បីលើកទឹកចិត្ត និងសំរបសំរួលដល់កិច្ចសហប្រតិបត្តិការអន្តរជាតិ សំដៅលុបបំបាត់ការប្រើប្រាស់ថ្នាំជួយក្នុងវិស័យកីឡា

ដោយមានកង្វល់ចំពោះការប្រើប្រាស់សារធាតុជួយដោយកីឡាករក្នុងការប្រកួតកីឡា និងផលវិបាករបស់វាចំពោះសុខភាពកីឡាករ ចំពោះគោលការណ៍នៃការប្រកួតស្មើភាព ការលុបបំបាត់ការបន្លំ និងអនាគតនៃវិស័យកីឡា

ដោយគិតថាការប្រើប្រាស់ថ្នាំជួយ អាចធ្វើអោយមានគ្រោះថ្នាក់ដល់គោលការណ៍ក្រមសីលធម៌ និងតំលៃអប់រំ ដែលមានចែងក្នុងធម្មនុញ្ញអន្តរជាតិស្តីពីការអប់រំកាយ និងកីឡារបស់ UNESCO និងក្នុងធម្មនុញ្ញអូឡាំពិក

ដោយនឹកឃើញថាអនុសញ្ញាប្រឆាំងនឹងការប្រើប្រាស់ថ្នាំជួយ និងពិធីសារបន្ថែមដែលបានអនុម័តក្នុងក្របខ័ណ្ឌរបស់ក្រុមប្រឹក្សាអឺរ៉ុប គឺជាឧបករណ៍ច្បាប់អន្តរជាតិសាធា-

រណៈ ដែលជាប្រភពដើមនៃគោលនយោបាយជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុ ដូប៉ា និងជាប្រភពដើមនៃកិច្ចសហប្រតិបត្តិការអន្តររដ្ឋាភិបាល

ដោយនឹកឃើញពីអនុសាសន៍ស្តីពីការប្រើប្រាស់សារធាតុដូប៉ា ដែលត្រូវបានអនុម័ត ដោយអនុសញ្ញាអន្តរជាតិលើកទី២ ទី៣ និងទី៤ របស់រដ្ឋមន្ត្រី និងឧត្តមមន្ត្រីទទួលបន្ទុក ការអប់រំកាយ និងកីឡា រៀបចំឡើងដោយ UNESCO នៅទីក្រុងមូស្គូ(១៩៨៨) នៅទីក្រុង ពុនតាដែលអេសស្តី (Punta Del Este) (១៩៩៩) និងទីក្រុងអាត់តែន(២០០៤) និងសេចក្តី សំរេចលេខ ៣២C/៩ ដែលត្រូវបានអនុម័តដោយមហាសន្និបាតរបស់ UNESCO ក្នុង សម័យប្រជុំលើកទី ៣២ (២០០៣)

ដោយចងចាំទុកក្នុងចិត្តនូវក្រមពិភពលោកស្តីពីការប្រឆាំងនឹងការប្រើប្រាស់សារ-ធាតុដូប៉ា ដែលត្រូវបានអនុម័ត ដោយទីភ្នាក់ងារពិភពលោកប្រឆាំងនឹងការប្រើប្រាស់ថ្នាំ ដូប៉ាក្នុងសន្និសីទពិភពលោកស្តីពីការប្រើថ្នាំដូប៉ាក្នុងកីឡានាទីក្រុងកូប៉ិនហាក (Copenhague) ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៣ និងសេចក្តីថ្លែងការណ៍របស់ទីក្រុងកូប៉ិនហាក ស្តីពីការ ប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា

ដោយគិតផងដែរពីឥទ្ធិពលដែលកីឡាករឆ្នើមៗមានលើយុវជន-យុវនារី

ដោយដឹងពីតំរូវការកំពុងកើតមាន ដើម្បីធ្វើ និងបង្កើនការសិក្សាស្រាវជ្រាវដោយ មានគោលដៅធ្វើអោយប្រសើរឡើងដល់ការរកឃើញនូវការប្រើប្រាស់សារធាតុដូប៉ា និង ការយល់ដឹងកាន់តែប្រសើរជាងមុនលើកត្តា ដែលជះឥទ្ធិពលលើការប្រើប្រាស់ ដើម្បីឱ្យ យុទ្ធសាស្ត្របង្ការទុកជាមុនមានប្រសិទ្ធភាព

ដោយយល់ដឹងផងដែរពីសារសំខាន់នៃការអប់រំកំពុងដំណើរការដល់កីឡាករ បុគ្គលិកគាំទ្រកីឡាករ និងទូទាំងសហគមន៍ក្នុងការរារាំងដល់ការប្រើប្រាស់សារធាតុដូប៉ា

ដោយគិតពីការចាំបាច់ចំពោះការកសាងសមត្ថភាពរបស់រដ្ឋជាភាគី ក្នុងការអនុវត្ត កម្មវិធីប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ា

ដោយយល់ដឹងថា អាជ្ញាធរសាធារណៈនិងអង្គការនានា ដែលទទួលបន្ទុកលើ វិស័យកីឡា មានការទទួលខុសត្រូវបន្ថែមក្នុងការបង្ការ និងប្រយុទ្ធប្រឆាំងនឹងការប្រើ ប្រាស់សារធាតុដូប៉ាក្នុងកីឡា ជាពិសេសគឺដើម្បីធានាឱ្យបាននូវការប្រព្រឹត្តសមស្របលើ គោលការណ៍នៃការប្រកួតដោយយុត្តិធម៌របស់វិញ្ញាសាកីឡា និងដើម្បីការពារសុខភាព របស់កីឡាករ ដែលចូលរួមប្រកួតក្នុងវិញ្ញាសាទាំងនោះ

ដោយទទួលស្គាល់ថាអាជ្ញាធរ និងអង្គការទាំងនេះត្រូវធ្វើការទាំងអស់គ្នាដើម្បីសំរេចឱ្យបាននូវគោលបំណងទាំងនេះ ដោយធានាអោយបាននូវកំរិតខ្ពស់បំផុតនៃឯករាជភាព និងតម្លាភាពនៅគ្រប់កំរិតសមស្របទាំងអស់

ដោយបានប្តេជ្ញាចិត្តបន្តកិច្ចសហប្រតិបត្តិការបន្ថែមទៀត និងកាន់តែរឹងមាំជាងមុន ក្នុងគោលបំណងលុបបំបាត់ការប្រើប្រាស់សារធាតុដូប៉ាំក្នុងវិស័យកីឡា

ដោយទទួលស្គាល់ថាការលុបបំបាត់ការប្រើប្រាស់សារធាតុដូប៉ាំក្នុងវិស័យកីឡា គឺអាស្រ័យដោយផ្នែកលើភាពជឿនលឿននៃសុខុមភាវូបនីយកម្មនៃស្តង់ដារ និងការអនុវត្តប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាំ និងការប្រតិបត្តិក្នុងកីឡា និងកិច្ចសហប្រតិបត្តិការថ្នាក់ជាតិ និងនៅកំរិតសកលលោក

អនុម័តអនុសញ្ញានេះនៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៥ ។

ផ្នែកទី ១ : ទិសាលភាព

មាត្រា ១.- គោលបំណងនៃអនុសញ្ញា

ក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីនៃសកម្មភាពរបស់ UNESCO អនុសញ្ញានេះ មានគោលបំណង ដើម្បីជំរុញការទប់ស្កាត់ និងការប្រយុទ្ធប្រឆាំងនឹងការប្រើប្រាស់សារធាតុជួយផ្នែកកីឡា ដោយមានទស្សនៈលុបបំបាត់អោយបាននូវការប្រើប្រាស់សារធាតុជួយទាំងនេះ ។

មាត្រា ២.- និយមន័យ

និយមន័យទាំងនេះ ត្រូវប្រើក្នុងបរិបទនៃក្រមសកលលោកស្តីពីការប្រឆាំងនឹងការប្រើប្រាស់សារធាតុជួយ។ ក៏ប៉ុន្តែ ក្នុងករណីមានជំលោះបទបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះត្រូវមានឧត្តមភាព ។

សំរាប់គោលបំណងនៃអនុសញ្ញានេះ:

១-មន្ទីរពិសោធន៍សំរាប់ត្រួតពិនិត្យការប្រើប្រាស់សារធាតុជួយ ដែលមានការទទួលស្គាល់ជាផ្លូវការ មានន័យថា បណ្តាមន្ទីរពិសោធន៍ ដែលទទួលស្គាល់ដោយទីភ្នាក់ងារសកលលោកប្រឆាំងនឹងការប្រើប្រាស់សារធាតុជួយ។

២-អង្គការប្រឆាំងនឹងការប្រើប្រាស់សារធាតុជួយ មានន័យថា ស្ថាប័នមួយដែលទទួលខុសត្រូវអនុម័តលើវិធាននានា សំរាប់ការចាប់ផ្តើម ការអនុវត្ត ឬប្រតិបត្តិផ្នែកណាមួយនៃដំណើរការត្រួតពិនិត្យការប្រើប្រាស់សារធាតុជួយ ។ ស្ថាប័នទាំងនេះ រួមមានជាឧទាហរណ៍ គណៈកម្មាធិការអូឡាំពិកអន្តរជាតិ គណៈកម្មាធិការប៉ារ៉ាអូឡាំពិកអន្តរជាតិ ស្ថាប័នផ្សេងៗទៀត ដែលទទួលបន្ទុករៀបចំព្រឹត្តិការណ៍ធំៗផ្សេងទៀត ដែលមានភារៈធ្វើតេស្តក្នុងវិញ្ញាសារបស់ពួកគេ ទីភ្នាក់ងារសកលលោកប្រឆាំងនឹងការប្រើប្រាស់សារធាតុជួយ សហព័ន្ធអន្តរជាតិ និងស្ថាប័នជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុជួយនានាទៀត។

៣-ការបំពានលើវិធានប្រឆាំងនឹងការប្រើប្រាស់សារធាតុជួយក្នុងកីឡាគឺជាអំពើតែមួយ ឬច្រើន ដូចមានចែងខាងក្រោមនេះ :

ក-វត្តមាននៃសារធាតុហាមឃាត់ ឬឥទ្ធិពលប្រែប្រួល ឬអាការៈនៃការប្រើប្រាស់ សារធាតុនេះក្នុងសំណាកគំរូ ដែលបានមកពីរាងកាយរបស់អត្តពលិក ។

9. **Transition**

In the period leading to a Convention or other obligation, participants may invite WADA to cooperate on a practical basis in order to assist in implementing the provisions of the Code in governments' field of authority.

Copenhagen Declaration on Anti-Doping in Sport

Signed on the 24th day of May in the year 2005

For the Government of: Royal Government of Cambodia

by

Name: Dr. KOL Pheng

Title: Senior Minister and Minister of Education Youth and Sports.

ខ-ការប្រើប្រាស់ ឬការប៉ុនប៉ងប្រើប្រាស់សារធាតុហាមឃាត់ ឬវិធីដែលគេហាមឃាត់ ។

គ-បដិសេធ ឬមិនបានមកបង្ហាញខ្លួនដើម្បីឱ្យគេប្រមូលយកសំណាកគំរូ ដោយគ្មានហេតុផលសមស្រប បន្ទាប់ពីទទួលបានការជូនដំណឹងដូចដែលបានតម្រូវក្នុងវិធានប្រឆាំងនឹងការប្រើប្រាស់សារធាតុផ្លូវការជាធរមាន ឬបើពុំនោះទេ គេចវេះពីការប្រមូលសំណាកគំរូ ។

ឃ-ការបំពានលើល័ក្ខខ័ណ្ឌតម្រូវជាធរមានស្តីពីវត្តមានរបស់កីឡាករ សំរាប់ការធ្វើតេស្តនៅក្រៅការប្រកួត ដោយរួមទាំងការមិនបានផ្តល់ព័ត៌មានចាំបាច់ពីទីកន្លែង និងការមិនបានមកធ្វើតេស្ត ដែលត្រូវបានគេប្រកាសដោយផ្អែកលើវិធានទាំងឡាយដែល សមហេតុផល ។

ង-រំខាន ឬប៉ុនប៉ងរំខានដល់ផ្នែកណាមួយនៃការត្រួតពិនិត្យរកការប្រើប្រាស់សារធាតុផ្លូវការ។

ច-មានសារធាតុ និងវិធីដែលគេហាមឃាត់។

ឆ-ចរាចរដោយលួចលាក់នូវសារធាតុហាមឃាត់ ឬវិធីដែលគេហាមឃាត់។

ជ-ឱ្យ ឬការប៉ុនប៉ងអោយសារធាតុហាមឃាត់ ឬវិធីដែលគេហាមឃាត់ទៅកីឡាករណាម្នាក់ ឬជួយជ្រោមជ្រែង លើកទឹកចិត្ត ជួយសម្រួល សមគំនិត បិទបាំង ឬការឃុបឃិតផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការបំពានលើវិធានប្រឆាំង នឹងការប្រើប្រាស់សារធាតុផ្លូវការ ឬការប៉ុនប៉ងបំពានផ្សេងទៀត។

៤-សំរាប់គោលបំណងនៃការត្រួតពិនិត្យរកការប្រើប្រាស់សារធាតុផ្លូវការ "អត្តពលិក" មានន័យថា បុគ្គលដែលចូលរួមប្រកួតក្នុងកីឡាណាមួយក្នុងកំរិតជាតិ និងអន្តរជាតិ ដូចបានកំណត់និយមន័យដោយស្ថាប័នជាតិ ប្រឆាំងនឹងការប្រើប្រាស់សារធាតុផ្លូវការនីមួយៗ និងដែលត្រូវបានទទួលយកដោយរដ្ឋជាភាគីនានា និងមានន័យទៀតថា បុគ្គលដែលជាអ្នកចូលរួមប្រកួតក្នុងកីឡា ឬវិញ្ញាសាមួយក្នុងកំរិតទាបជាងនេះ ដែលត្រូវបានទទួលយកដោយរដ្ឋជាភាគី។សំរាប់គោលបំណងនៃកម្មវិធីអប់រំ និងបណ្តុះបណ្តាល "អត្តពលិក" មានន័យថា ជនទាំងឡាយណាដែលចូលរួមក្នុងការប្រកួត កីឡាក្រោមអំណាចរបស់ស្ថាប័នកីឡា ។

៥-បុគ្គលិកជំនួយអត្តពលិក មានន័យថា ជាគ្រូបង្វឹក អ្នកហ្វឹកហ្វឺន អ្នកគ្រប់-គ្រង ភ្នាក់ងារ បុគ្គលិកក្រុមមន្ត្រី បុគ្គលិកវេជ្ជសាស្ត្រ បុគ្គលិកអមវេជ្ជសាស្ត្រ ដែលជាអ្នកធ្វើការជាមួយ ឬបំរើអត្តពលិក ដែលចូលរួមប្រកួត ឬរៀបចំសំរាប់ការប្រកួតប្រជែងកីឡា ។

៦-ក្រម មានន័យថា ជាក្រមសកលលោកប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ា ដែលអនុម័តដោយទីភ្នាក់ងារសកលលោកប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ា នៅថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៣ នៅទីក្រុងកូប៉ិនហាក ដែលត្រូវបានដាក់ភ្ជាប់មកជាមួយជាឧបសម្ព័ន្ធលេខ ១ នៃអនុសញ្ញានេះ ។

៧-ការប្រកួត មានន័យថាជាការប្រណាំងទោល ការប្រកួត ហ្គេម ឬការប្រកួតអត្តពលកម្មទោល ។

៨-ការត្រួតពិនិត្យលើការប្រើប្រាស់សារធាតុដូប៉ា មានន័យថា ជាដំណើរការរួមមាន ការធ្វើផែនការបែងចែកតេស្ត ការប្រមូលនិងការគ្រប់គ្រងសំណាកគំរូ ការវិភាគរបស់មន្ទីរពិសោធន៍ ការគ្រប់គ្រងលទ្ធផល និងការជំនុំជំរះការតវ៉ា ។

៩-ការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា មានន័យថា ជាការកើតឡើងនៃការបំពានលើវិធានប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ា។

១០-ក្រុមទទួលបន្ទុកត្រួតពិនិត្យការប្រើប្រាស់សារធាតុដូប៉ាដែលទទួល បានការអនុញ្ញាតត្រឹមត្រូវ មានន័យថា ជាក្រុមត្រួតពិនិត្យការប្រើប្រាស់សារធាតុដូប៉ា ដែលធ្វើប្រតិបត្តិការ ក្រោមអំណាចរបស់ស្ថាប័នជាតិ ឬអន្តរជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ា។

១១- ក្នុងគោលបំណងញែកអោយដាច់ពីគ្នារវាងការធ្វើតេស្តក្នុងពេលប្រកួត និងក្រៅការប្រកួត ការធ្វើតេស្ត ក្នុងពេលប្រកួត មានន័យថា ជាការធ្វើតេស្តមួយដែលក្នុងនោះ អត្តពលិកម្នាក់ត្រូវបានគេជ្រើសរើសសំរាប់ការធ្វើតេស្ត ដែលទាក់ទងទៅនឹង ការប្រកួតជាក់លាក់មួយ លើកលែងតែមានចែងផ្សេងពីនេះ នៅក្នុងវិធានរបស់សហព័ន្ធអន្តរជាតិ ឬស្ថាប័នប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាផ្សេងទៀត ដែលពាក់ព័ន្ធ។

១២- ស្តង់ដារអន្តរជាតិសំរាប់មន្ទីរពិសោធន៍ មានន័យថា ជាស្តង់ដារដែលត្រូវបានដាក់ភ្ជាប់មកជាមួយជាឧបសម្ព័ន្ធលេខ ២ ក្នុងអនុសញ្ញានេះ ។

១៣-ស្តង់ដារអន្តរជាតិសំរាប់ការធ្វើតេស្ត មានន័យថា ជាស្តង់ដារដែលត្រូវបានដាក់ភ្ជាប់មកជាមួយជាឧបសម្ព័ន្ធលេខ ៣ ក្នុងអនុសញ្ញានេះ ។

១៤. គ្មានការជូនដំណឹងជាមុន មានន័យថា ជាការត្រួតពិនិត្យលើការប្រើប្រាស់សារធាតុដូប៉ា ដែលធ្វើឡើងដោយគ្មានផ្តល់ការព្រមានជាមុនដល់អត្តពលិក និងនៅកន្លែងណាដែលអត្តពលិកត្រូវបានតាមដានត្រួតពិនិត្យជាបន្តបន្ទាប់ គិតចាប់ពីពេលនៃការជូនដំណឹង រហូតដល់ការផ្តល់សំណាកគំរូ ។

១៥-ចលនាអូឡាំពិក មានន័យថា ជាជនទាំងឡាយណា ដែលយល់ព្រមអនុវត្តតាមធម្មនុញ្ញអូឡាំពិក និងជាអ្នកដែលទទួលស្គាល់សិទ្ធិអំណាចរបស់គណៈកម្មាធិការអូឡាំពិកអន្តរជាតិ មានដូចជាៈ សហព័ន្ធអន្តរជាតិ នៃកីឡាសំរាប់កម្មវិធីរបស់ហ្គេមអូឡាំពិក គណៈកម្មាធិការជាតិអូឡាំពិក គណៈកម្មាធិការរៀបចំអូឡាំពិកហ្គេម អត្តពលិកចៅក្រម និងអាជ្ញាកណ្តាល សមាគម និងក្លឹប ក៏ដូចជាអង្គការ និងស្ថាប័នទាំងអស់ ដែលត្រូវបានទទួលស្គាល់ដោយគណៈកម្មាធិការអូឡាំពិកអន្តរជាតិ។

១៦-ការត្រួតពិនិត្យការប្រើប្រាស់សារធាតុដូប៉ានៅក្រៅការប្រកួត មានន័យថា ជាការត្រួតពិនិត្យលើការប្រើប្រាស់សារធាតុដូប៉ាណាមួយ ដែលមិនត្រូវបានធ្វើឡើងនៅក្នុងពេលប្រកួត ។

១៧- បញ្ជីហាមឃាត់ មានន័យថា ជាបញ្ជីដែលមានក្នុងឧបសម្ព័ន្ធទី ១ នៃអនុសញ្ញានេះ ដែលកំណត់ពីសារធាតុហាមឃាត់ និងវិធីដែលគេហាមឃាត់ ។

១៨- វិធីហាមឃាត់ មានន័យថា ជាវិធីណាមួយ ដែលត្រូវបានពិពណ៌នាក្នុងបញ្ជីហាមឃាត់ ដែលមានក្នុងឧបសម្ព័ន្ធទី ១ នៃអនុសញ្ញានេះ ។

១៩- សារធាតុហាមឃាត់ មានន័យថា ជាសារធាតុ ដែលបានពិពណ៌នាក្នុងបញ្ជីហាមឃាត់ ដែលមានក្នុងឧបសម្ព័ន្ធទី ១ នៃអនុសញ្ញានេះ។

២០-អង្គការកីឡា មានន័យថាជាអង្គការមួយ ដែលដើរតួជាស្ថាប័នគ្រប់គ្រងលើវិញ្ញាសាមួយសំរាប់កីឡាមួយ ឬច្រើនប្រភេទ ។

២១-ស្តង់ដារសំរាប់ផ្តល់ការលើកលែងលើការប្រើប្រាស់សំរាប់ព្យាបាលជម្ងឺ មានន័យថា ជាស្តង់ដារទាំងឡាយណា ដែលមានក្នុងឧបសម្ព័ន្ធទី ២ នៃអនុសញ្ញានេះ ។

២២- ការធ្វើតេស្ត មានន័យថា ជាផ្នែកនានានៃដំណើរការត្រួតពិនិត្យលើការប្រើប្រាស់សារធាតុដូប៉ាដែលពាក់ព័ន្ធនឹងការធ្វើផែនការបែងចែកតេស្ត ការប្រមូលសំណាកគំរូ ការទុកដាក់សំណាកគំរូ និងការដឹកជញ្ជូនសំណាកគំរូទៅមន្ទីរពិសោធន៍ ។

២៣-ការលើកលែងលើការប្រើប្រាស់សំរាប់ព្យាបាលជម្ងឺ មានន័យថា ជាការលើកលែង ដែលគេផ្តល់អោយស្របតាមស្តង់ដារសំរាប់ការ ផ្តល់ការលើកលែងលើការព្យាបាលជម្ងឺ។

២៤- ការប្រើប្រាស់ មានន័យថា ជាការយកមកបិទឬលាប ការលេបតាមមាត់ ការចាក់បញ្ចូល ឬការប្រើប្រាស់សារធាតុ ឬវិធីដែលគេហាមឃាត់ណាមួយ ទោះជាតាមវិធីណាក៏ដោយ ។

២៥- ទីភ្នាក់ងារសកលលោកប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ា (World Anti-Doping Agency ហៅកាត់ថា WADA) មានន័យថា ជាមូលនិធិ ដែលត្រូវបានបង្កើតឡើងក្រោមច្បាប់របស់ប្រទេសស្វីស នៅថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ១៩៩៩។

មាត្រា ៣.- មធ្យោបាយដើម្បីសំរេចបាននូវគោលបំណងនៃអនុសញ្ញានេះ

ដើម្បីសំរេចបាននូវគោលបំណងនៃអនុសញ្ញានេះ រដ្ឋជាភាគីទាំងឡាយត្រូវបំពេញការងារដូចខាងក្រោម :

១-អនុម័តវិធានការសមស្របនៅថ្នាក់ជាតិ និងអន្តរជាតិ ដែលអនុលោមតាមគោលការណ៍របស់ច្បាប់នេះ

២-លើកទឹកចិត្តឱ្យមានកិច្ចសហប្រតិបត្តិការអន្តរជាតិគ្រប់ទំរង់ទាំងអស់ ក្នុងគោលបំណងការពារអត្តពលិកក្រមសីលធម៌ក្នុងកីឡា និងការចែករំលែកលទ្ធផលនៃការសិក្សាស្រាវជ្រាវ

៣-លើកស្ទួយកិច្ចសហប្រតិបត្តិការអន្តរជាតិរវាងរដ្ឋជាភាគី និងស្ថាប័ននាំមុខនានាក្នុងការប្រយុទ្ធប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងកីឡា ជាពិសេសជាមួយ WADA ។

មាត្រា ៤.- ទំនាក់ទំនងនៃអនុសញ្ញានេះជាមួយនិងក្រម

១-ដើម្បីសំរបសំរួលដល់ការអនុវត្តនៅថ្នាក់ជាតិ និងអន្តរជាតិ សំដៅប្រយុទ្ធប្រឆាំងការប្រើប្រាស់សារធាតុដូប៉ាក្នុងវិស័យកីឡា រដ្ឋជាភាគីទាំងឡាយប្តេជ្ញាអនុវត្តតាមគោលការណ៍របស់ក្រម ដោយចាត់ទុកថាជា មូលដ្ឋានសំរាប់វិធានការទាំងឡាយដូចមានចែងក្នុងមាត្រា ៥ នៃអនុសញ្ញានេះ។ គ្មានបញ្ញត្តិណាមួយក្នុងអនុសញ្ញានេះធ្វើការរារាំងដល់រដ្ឋជាភាគីទាំងឡាយមិនអោយប្រើប្រាស់នូវវិធានការបន្ថែមដែលបំពេញបង្គ្រប់ក្រមនេះឡើយ ។

២-ច្បាប់ និងឯកសារបន្ថែមទី ២ និងទី៣ ថ្មីៗចុងក្រោយបំផុត ត្រូវបានធ្វើឡើងវិញ សំរាប់គោលបំណងផ្សព្វផ្សាយព័ត៌មានប៉ុណ្ណោះ មិនមែនជាផ្នែកសំខាន់ចាំបាច់មិនអាចខ្វះបានមួយនៃអនុសញ្ញានេះឡើយ ។ ឯកសារបន្ថែមទាំងនេះ មិនចងភ្ជាប់កាតព្វកិច្ច ក្រោមច្បាប់អន្តរជាតិសំរាប់រដ្ឋជាភាគីទាំងឡាយឡើយ ។

៣-ឧបសម្ព័ន្ធទើបជាផ្នែកសំខាន់ចាំបាច់មិនអាចខ្វះបានមួយនៃអនុសញ្ញានេះ ។

មាត្រា ៥.- វិធានការនានាដើម្បីសំរេចបាននូវគោលបំណងនៃអនុសញ្ញានេះ

ដើម្បីអនុលោមតាមកាតព្វកិច្ចដែលមានចែងក្នុងអនុសញ្ញានេះ រដ្ឋជាភាគីនីមួយៗ ទទួលខុសត្រូវក្នុងការអនុម័តវិធានការសមស្របនានា។ វិធានការទាំងនេះអាចមានដូចជា ច្បាប់ បទបញ្ញា គោលនយោបាយ ឬការអនុវត្តផ្នែករដ្ឋបាល ។

មាត្រា ៦.- ទំនាក់ទំនងចំពោះលិខិតុបករណ៍អន្តរជាតិដទៃទៀត

អនុសញ្ញានេះមិនត្រូវធ្វើការកែប្រែសិទ្ធិ និងកាតព្វកិច្ចរបស់រដ្ឋជាភាគី ដែលកើតឡើងមកពីកិច្ចព្រមព្រៀងផ្សេងទៀត ដែលបានធ្វើឡើងកាលពីលើកមុន និងដែលស្របតាមកម្មវត្ថុ និងគោលបំណងនៃអនុសញ្ញានេះឡើយ។ ទាំងនេះមិនប៉ះពាល់ដល់ការអនុវត្តសិទ្ធិ ឬការអនុវត្តកាតព្វកិច្ចរបស់រដ្ឋជាភាគីនានា ក្រោមអនុសញ្ញានេះឡើយ ។

ផ្នែកទី ២ : សកម្មភាពប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាំថ្នាក់ជាតិ

មាត្រា ៧.- ការសំរបសំរួលក្នុងស្រុក

រដ្ឋជាភាគីទាំងឡាយត្រូវធានាឱ្យបាននូវការអនុវត្តអនុសញ្ញាបច្ចុប្បន្ននេះ ជាពិសេសតាមរយៈការសំរបសំរួលក្នុងស្រុក ។ ដើម្បីបំពេញបាននូវកាតព្វកិច្ចរបស់រដ្ឋជាភាគីទាំងឡាយក្រោមអនុសញ្ញានេះ រដ្ឋជាភាគីអាចពឹងពាក់អាស្រ័យលើស្ថាប័នប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាំនានា ក៏ដូចជាអាជ្ញាធរ និងស្ថាប័នកីឡាដែរ ។

មាត្រា ៨.- ការដាក់កំហិតចំពោះភាពអាចរកបាននិងការប្រើប្រាស់សារធាតុ និងវិធីហាមឃាត់ក្នុងកីឡា

១-នៅពេលសមស្រប រដ្ឋជាភាគីទាំងឡាយត្រូវអនុម័តលើវិធានការ ដើម្បីដាក់កំហិតលើភាពអាចរកបាននៃសារធាតុ និងវិធីហាមឃាត់ សំដៅដាក់កំហិតលើការប្រើប្រាស់សារធាតុ និងវិធីហាមឃាត់ទាំងនេះ ដោយអត្តពលិក វៀរលែងតែការប្រើប្រាស់នេះ មានមូលដ្ឋានលើការលើកលែងការប្រើប្រាស់សំរាប់ព្យាបាលជម្ងឺ។ វិធានការទាំងនេះមានដូចជា វិធានការប្រឆាំងនឹងការលួចផ្តល់ឱ្យអត្តពលិក ហើយនិងវិធានការដើម្បីត្រួតពិនិត្យលើផលិតកម្ម ចលនា ការនាំចូល ការចែកចាយ និងការលក់ ។

២-នៅពេលសមស្រប រដ្ឋជាភាគីទាំងឡាយត្រូវអនុម័ត ឬលើកទឹកចិត្តដល់ស្ថាប័នពាក់ព័ន្ធ ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ឱ្យអនុម័តនូវវិធានការ ដើម្បីរារាំង និងដាក់កំហិតលើការប្រើប្រាស់ និងការកាន់កាប់សារធាតុ និងវិធីហាមឃាត់ទាំងនេះដោយអត្តពលិកអ្នកលេងកីឡា វៀរលែងតែការប្រើប្រាស់នេះ មានមូលដ្ឋានលើការលើកលែងការប្រើប្រាស់សំរាប់ព្យាបាលជម្ងឺ ។

៣-គ្មានវិធានការណាមួយដែលត្រូវបានគេចាត់ឡើងស្របតាមអនុសញ្ញានេះ នឹងរារាំងដល់ភាពអាចរកបាន សំរាប់គោលបំណងស្របច្បាប់នៃសារធាតុ និងវិធីដែលត្រូវគេហាមឃាត់ និងត្រួតត្រាផ្សេងពីនេះ ក្នុងកីឡាឡើយ ។

មាត្រា ៩.- វិធានការប្រឆាំងនឹងបុគ្គលិកជំនួយអត្តពលិក

រដ្ឋជាភាគីទាំងឡាយត្រូវចាត់វិធានការដោយខ្លួនឯងផ្ទាល់ ឬលើកទឹកចិត្តស្ថាប័នកីឡា និងស្ថាប័នប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ា អោយអនុម័តនូវវិធានការនានារួមទាំងការដាក់ទណ្ឌកម្ម ឬការពិន័យលើបុគ្គលិក ជំនួយអត្តពលិក ដែលបានប្រព្រឹត្តបំពានលើវិធានប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ា ឬបានប្រព្រឹត្តបទល្មើសដទៃទៀតដែលពាក់ព័ន្ធជាមួយនឹងការប្រើប្រាស់សារធាតុដូប៉ាក្នុងកីឡា ។

មាត្រា ១០.- ចំណីអាហារបំពេញបន្ថែម

នៅពេលសមស្រប រដ្ឋជាភាគីទាំងឡាយត្រូវលើកទឹកចិត្តឱ្យអ្នកផលិត និងអ្នកចែកចាយអាហារបំប៉នជីវជាតិ បង្កើតការអនុវត្តល្អក្នុងការផ្សព្វផ្សាយរកទីផ្សារ និងចែកចាយលក់សារធាតុបំប៉នជីវជាតិ រួមទាំងព័ត៌មានស្តីពីសមាសភាពវិភាគរបស់ថ្នាំបំប៉នទាំងនេះ និងការធានាលើគុណភាព។

មាត្រា ១១.- វិធានការហិរញ្ញវត្ថុ

នៅពេលសមស្រប រដ្ឋជាភាគីទាំងឡាយត្រូវ :

ក-ផ្តល់ថវិកានៅក្នុងគំរោងថវិការបស់ខ្លួន ដើម្បីទ្រទ្រង់ដល់កម្មវិធីធ្វើតេស្តជាតិមួយលើកីឡាទាំងអស់ ឬជួយដល់ស្ថាប័នកីឡា និងស្ថាប័នប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ា ឱ្យផ្តល់ថវិកាដល់ការត្រួតពិនិត្យលើការប្រើប្រាស់សារធាតុដូប៉ា តាមបែបប្រាក់ឧបត្ថម្ភផ្ទាល់ ឬអំណោយ ឬដោយទទួលស្គាល់សោហ៊ុយចំណាយនៃការត្រួតពិនិត្យនេះជាមួយនឹងការកំណត់ប្រាក់ឧបត្ថម្ភ ឬអំណោយទាំងអស់ ដែលជាការលើកទឹកចិត្តដល់ស្ថាប័នទាំងនោះ ។

ខ-ចាត់វិធានការដើម្បីដកទុកជំនួយគាំទ្រផ្នែកហិរញ្ញវត្ថុ ដែលពាក់ព័ន្ធនឹងកីឡាចំពោះអត្តពលិកម្នាក់ៗ ឬបុគ្គលិក ជំនួយអត្តពលិក ដែលត្រូវបានគេព្យួរការងារ បន្ទាប់ពីបានបំពានលើវិធានប្រឆាំងថ្នាំដូប៉ា ក្នុងអំឡុងពេលព្យួរការងាររបស់ពួកគេ ។

គ-ដកទុកជំនួយគាំទ្រផ្នែកហិរញ្ញវត្ថុខ្លះ ឬទាំងអស់ ឬជំនួយគាំទ្រផ្សេងទៀតដែលពាក់ព័ន្ធនឹងកីឡាពីស្ថាប័នកីឡាណាមួយ ឬស្ថាប័នប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ា ដែលមិនអនុវត្តតាមច្បាប់ ឬវិធានជាធរមាន ប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ា ដែលត្រូវបានគេអនុម័តស្របទៅតាមក្រម។

មាត្រា ១២.- វិធានការដើម្បីសំរួលដល់ការត្រួតពិនិត្យលើការប្រើប្រាស់សារធាតុដូប៉ា

នៅទីណាដែលសមស្រប រដ្ឋជាភាគីទាំងឡាយត្រូវ :

ក-លើកទឹកចិត្ត និងសំរួលដល់ស្ថាប័នកីឡា ឬស្ថាប័នប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ា ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន អោយអនុវត្តនូវការត្រួតពិនិត្យលើការប្រើប្រាស់សារធាតុដូប៉ាក្នុងលក្ខណៈមួយ ដែលស្របតាមច្បាប់ ដោយរាប់បញ្ចូលទាំងការមិនផ្តល់ដំណឹងទុកជាមុន ការធ្វើតេស្តនៅក្រៅការប្រកួត និងក្នុងការប្រកួត។

ខ-លើកទឹកចិត្ត និងសំរួលដល់ការចរចាដោយស្ថាប័នកីឡា ឬស្ថាប័នប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ា ស្តីពីកិច្ចព្រមព្រៀងដែលអនុញ្ញាតអោយសមាជិករបស់ស្ថាប័នទាំងនេះ ត្រូវបានគេធ្វើតេស្តដោយក្រុមត្រួតពិនិត្យការប្រើប្រាស់សារធាតុដូប៉ា ដែលទទួលបានសិទ្ធិស្របច្បាប់។

គ-ធ្វើការជួយដល់ស្ថាប័នកីឡា ឬស្ថាប័នប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ា ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ឱ្យទទួលបានសេវារបស់មន្ទីរពិសោធន៍ត្រួតពិនិត្យ

លើការប្រើប្រាស់សារធាតុជួយ ដែលមានការទទួលស្គាល់ជាផ្លូវការសំរាប់គោលបំណង វិភាគលើការត្រួតពិនិត្យលើការប្រើប្រាស់សារធាតុជួយ។

ផ្នែកទី ៣ : កិច្ចសហប្រតិបត្តិការអន្តរជាតិ

មាត្រា ១៣.- កិច្ចសហប្រតិបត្តិការរវាងស្ថាប័នកីឡា និងស្ថាប័នប្រឆាំងនឹងការប្រើប្រាស់សារធាតុជួយ

រដ្ឋជាភាគីទាំងឡាយត្រូវលើកទឹកចិត្តដល់កិច្ចសហប្រតិបត្តិការរវាងស្ថាប័នប្រឆាំងនឹងការប្រើប្រាស់សារធាតុជួយ អាជ្ញាធរសាធារណៈ និងស្ថាប័នកីឡាដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន និងបណ្តាស្ថាប័ន ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់រដ្ឋជាភាគីផ្សេងទៀត ដើម្បីសំរេចបាននូវគោលបំណងទាំងឡាយនៃអនុសញ្ញានេះក្នុងកំរិតអន្តរជាតិ ។

មាត្រា ១៤.- ការគាំទ្រដល់បេសកកម្មរបស់ WADA

រដ្ឋជាភាគីទាំងឡាយធ្វើការគាំទ្រដល់បេសកកម្មដ៏មានសារសំខាន់របស់ WADA ក្នុងការប្រយុទ្ធជាអន្តរជាតិប្រឆាំងនឹងការប្រើប្រាស់សារធាតុជួយ។

មាត្រា ១៥.- ការផ្តល់ថវិកាស្មើគ្នាសំរាប់ WADA

រដ្ឋជាភាគីទាំងឡាយ គាំទ្រដល់គោលការណ៍នៃការផ្តល់ថវិកាស្មើគ្នាសំរាប់គំរោងថវិកាស្នូលប្រចាំឆ្នាំរបស់WADA ដែលទទួលបាននូវការឯកភាពពីបណ្តាអាជ្ញាធរសាធារណៈ និងចលនាអូឡាំពិក ។

មាត្រា ១៦.- កិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការត្រួតពិនិត្យលើការប្រើប្រាស់សារធាតុជួយ

ដោយទទួលស្គាល់ថាការប្រយុទ្ធប្រឆាំងនឹងការប្រើប្រាស់សារធាតុជួយក្នុងវិស័យកីឡា អាចមានប្រសិទ្ធភាព តែនៅពេលណាដែលអត្តពលិកត្រូវបានធ្វើតេស្ត ដោយមិនបានផ្តល់ដំណឹងជាមុន ហើយសំណាកគំរូអាចត្រូវបានដឹកជញ្ជូនទាន់ពេលវេលាទៅកាន់មន្ទីរពិសោធន៍ ដើម្បីធ្វើការវិភាគនៅពេលសមស្រប និងដោយអនុលោមទៅតាមច្បាប់ និងនីតិវិធីក្នុងប្រទេស រដ្ឋជាភាគីទាំងឡាយត្រូវអនុវត្តតាម ចំនុចខាងក្រោមនេះ :

ក-សម្រួលដល់ការងាររបស់ WADA និងស្ថាប័នប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ា ដែលប្រតិបត្តិស្របទៅតាមក្រម (ស្ថិតក្រោមបទបញ្ជាដែលពាក់ព័ន្ធរបស់ប្រទេសជាម្ចាស់ផ្ទះ) ធ្វើក្នុងការត្រួតពិនិត្យលើការប្រើប្រាស់សារធាតុដូប៉ាក្នុងពេលប្រកួត ឬនៅក្រៅការប្រកួតទៅលើអត្តពលិករបស់ខ្លួន ទោះបីនៅក្នុងទឹកដីរបស់ខ្លួនផ្ទាល់ក្តី ឬនៅកន្លែងណាផ្សេងទៀតក្តី ។

ខ-ជួយសម្រួលដល់ការធ្វើដំណើរអោយឆ្លងកាត់ព្រំដែនទាន់ពេលវេលារបស់ក្រុមត្រួតពិនិត្យលើការប្រើប្រាស់សារធាតុដូប៉ា នៅពេលធ្វើសកម្មភាពត្រួតពិនិត្យលើការប្រើប្រាស់សារធាតុដូប៉ា។

គ-ធ្វើសហប្រតិបត្តិការ ដើម្បីជួយជំរុញឱ្យបានឆាប់រហ័សដល់ការដឹកជញ្ជូន ឬការបញ្ជូនសំណាកគំរូអោយឆ្លងកាត់តាមព្រំដែនទាន់ពេលវេលា ក្នុងរបៀបមួយដើម្បីថែរក្សាសុវត្ថិភាព និងភាពគង់វង្សនៃសំណាកគំរូទាំងនេះ ។

ឃ-ជួយដល់កិច្ចសំរបសំរួលជាអន្តរជាតិក្នុងការត្រួតពិនិត្យលើការប្រើប្រាស់សារធាតុដូប៉ា ដោយស្ថាប័ននានា ដែលប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ា និងធ្វើកិច្ចសហប្រតិបត្តិការជាមួយWADA ចំពោះបញ្ហានេះ ។

ង-ជំរុញកិច្ចសហប្រតិបត្តិការរវាងមន្ទីរពិសោធន៍ត្រួតពិនិត្យលើការប្រើប្រាស់សារធាតុដូប៉ា ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន និងមន្ទីរពិសោធន៍នានា ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់រដ្ឋជាភាគីផ្សេងទៀត។ជាពិសេស រដ្ឋជាភាគីទាំងឡាយដែលមានមន្ទីរពិសោធន៍ត្រួតពិនិត្យការប្រើសារធាតុដូប៉ា ដែលត្រូវបានទទួលស្គាល់ជាផ្លូវការគួរលើកទឹកចិត្តដល់មន្ទីរពិសោធន៍នានា ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន អោយជួយដល់ភាគីរដ្ឋផ្សេងទៀត ក្នុងការផ្តល់លទ្ធភាពអោយពួកគេទទួលបាននូវបទពិសោធន៍ជំនាញ និងបច្ចេកទេសដែលចាំបាច់ដើម្បីបង្កើតមន្ទីរពិសោធន៍ផ្ទាល់របស់ខ្លួន ប្រសិនបើរដ្ឋជាភាគីនោះ មានបំណងចង់បង្កើត ។

ច-លើកទឹកចិត្ត និងគាំទ្រទៅវិញទៅមកដល់ការរៀបចំធ្វើតេស្តរវាងស្ថាប័នប្រឆាំងនឹងការប្រើប្រាស់សារធាតុដូប៉ាទាំងឡាយ ដែលទទួលបានការចាត់តាំងដោយអនុលោមតាមក្រម ។

ឆ-ទទួលស្គាល់ទៅវិញទៅមកនូវនីតិវិធីត្រួតពិនិត្យលើការប្រើប្រាស់សារធាតុដូប៉ា និងការគ្រប់គ្រងលើលទ្ធផលនៃការធ្វើតេស្តរបស់ស្ថាប័នប្រឆាំងនឹងការប្រើប្រាស់សារធាតុ

